


# ប្រទេសជប៉ុន និង ទំនាក់ទំនងជាមួយកម្ពុជា

# មាតិកា


ទំព័រ

សាររបស់ឯកអគ្គរាជទូតជប៉ុន .................................... ១

ព្រឹត្តិការណ៍តាមរដូវនៅប្រទេសជប៉ុន ......................... ២-៣

ភូមិសាស្ត្រ និងធម្មជាតិ ............................................ ៤-៥

លំនៅស្ថាន អាហារ និងសម្លៀកបំពាក់ ....................... ៦-៧

ការអប់រំ និងប្រវត្តិសាស្ត្រ ......................................... ៨-១១

វប្បធម៌ និងកីឡា ...................................................... ១២-១៥

រាជវង្សានុវង្ស .......................................................... ១៦

ស្ថាប័នរដ្ឋ .................................................................. ១៧

សេដ្ឋកិច្ច ឧស្សាហកម្ម និងបច្ចេកវិទ្យា ........................ ១៨-១៩

ប្រវត្តិមិត្តភាពជប៉ុន-កម្ពុជា .......................................... ២០

ជប៉ុន-កម្ពុជាវិស័យសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការ...... ២១-២៣

អតីតនិស្សិតអាហារូបករណ៍ និងព័ត៌មានអាហារូបករណ៍... ២៤

ដំណើរទៅកាន់ប្រទេសជប៉ុន និងការសន្ទនាខ្លីៗ............. ២៦

ប្រតិទិនព្រឹត្តិការណ៍កម្មវិធីជប៉ុន និងវិទ្យាស្ថានអប់រំភាសា

ជប៉ុននៅកម្ពុជា ........................................................ ២៨




© MITSUHIRO OUCHI/ a.collectionRF/amanaimages



JNTO



JNTO



© Taito City / © JNTO

# ខុននីឈិវ៉ា ជម្រាបសួរ ប្រជាជនកម្ពុជាទាំងអស់គ្នា!

ខ្ញុំឈ្មោះ **មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា។ ខ្ញុំបានមកដល់កម្ពុជានៅខែកញ្ញា ឆ្នាំ២០១៩។ ខ្ញុំភ្ញាក់ផ្អើលនឹងការរីកចម្រើនខ្លាំងរបស់កម្ពុជា បើប្រៀបធៀបកាលដែលខ្ញុំធ្លាប់មកកាលពីឆ្នាំ២០០២។ លើសពីនេះទៀត ខ្ញុំរីករាយដែលបានឃើញជនជាតិជប៉ុនកំពុងចែករំលែកបទពិសោធន៍របស់ខ្លួន តាមរយៈកិច្ចការធុរកិច្ច និងគម្រោងសហប្រតិបត្តិការនានា នៅទីកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជា។



**មិកាមិ ម៉ាសាហ៊ីរ៉ូ**

ឯកអគ្គរាជទូតជប៉ុន

ប្រចាំព្រះរាជាណាចក្រកម្ពុជា

តើលោក លោកស្រី ក្មួយៗមានទស្សនៈយ៉ាងណាអំពីប្រទេសជប៉ុន? អ្នកខ្លះបានយល់ឃើញថាប្រទេសជប៉ុន គឺជាប្រទេសរីកចម្រើនខ្លាំងខាងបច្ចេកវិទ្យា ប៉ុន្តែជាក់ស្តែងប្រទេសជប៉ុន ក៏ជាប្រទេសដែលបានថែរក្សាវប្បធម៌ប្រពៃណី និងសម្បត្តិធម្មជាតិផងដែរ។

ខ្ញុំសង្ឃឹមថាតាមរយៈទស្សនាវដ្តីនេះ ប្រជាជនកម្ពុជានឹងចាប់អារម្មណ៍អំពីប្រទេសជប៉ុនបន្ថែមទៀត។

ខែមករា ឆ្នាំ២០២០



ឈ្មោះ៖ ប្រទេសជប៉ុន

ទីតាំង៖ អាស៊ីខាងកើត

ផ្ទៃដី៖ ៣៧៨.០០០ គីឡូម៉ែត្រការ៉េ

ចំនួនប្រជាជន៖ ១២៧លាននាក់

ភាសា៖ ភាសាជប៉ុន

រាជធានី៖ ទីក្រុងតូក្យូ

រូបិយវត្ថុ៖ យ៉េន (និមិត្តិសញ្ញា ¥ )

ប្រទេសជប៉ុនព័ទ្ធជុំវិញដោយសមុទ្រហើយបីភាគបួននៃប្រទេសគឺជាភ្នំ ដោយមានទំនាប និងទឹកគ្របដណ្តប់លើផ្ទៃដីដែលនៅសល់។ ចរន្តទឹកក្តៅ និងទឹកត្រជាក់ដែលហូរកាត់សមុទ្រជុំវិញប្រទេស បង្កើតជាបរិស្ថានមួយដែលអំណោយផលដល់ការរស់នៅរបស់ត្រីជាច្រើនប្រភេទ។

# ព្រឹត្តិការណ៍តាមរដូវនៅប្រទេសជប៉ុន

ប្រទេសជប៉ុនមានបួនរដូវ ហើយក្នុងរដូវនីមួយៗមានពិធីបុណ្យប្រពៃណីផ្សេងៗគ្នា។ ក្នុងឱកាសពិធីបុណ្យទាំងនោះ សមាជិកគ្រួសារទាំងអស់ជួបជុំគ្នា ហើយចូលរួមសប្បាយរីករាយទាំងអស់គ្នា។





### និវាកុមារ (ថ្ងៃទី៥ ខែឧសភា)

ថ្ងៃទី៥ ខែឧសភា នៅតាមផ្ទះនីមួយៗក្នុងសួនច្បារ មានព្យួររូបត្រីធំៗ (កយណុប៉ូរី) ដែលធ្វើពីក្រណាត់ ។ រូបត្រីនោះគឺជាត្រីគល់រាំង ជាត្រីខ្លាំងដែលអាចហែលបញ្ច្រាសទិសដៅទឹកហូរ។ នេះជានិមិត្តរូបនៃកម្លាំងខ្លាំង និងសុខភាពល្អរបស់ក្មេងៗ។



### ហ៊ីណាម៉ាត់ស៊ូរិ (បុណ្យកុមារី) (ថ្ងៃទី៣ ខែមីនា)

ពិធីបុណ្យនៅថ្ងៃទី៣ ខែមីនានេះ ប្រារព្ធឡើងដើម្បីបួងសួងឲ្យក្មេងស្រីមានសុខភាពល្អ។ គ្រួសារដែលមានកូនស្រី តុបតែងតាំងរូបតុក្កតាដែលមានជើងទម្រស្លៀកសំលៀកបំពាក់រាជវាំងសម័យបុរាណ។



### សឹតស៊ឹប៊ឹន(ពិធីបាចសណ្ដែកសៀង) (ថ្ងៃទី៣ ខែកុម្ភៈ)

ពិធីនេះគឺជាពិធីបុណ្យបុរាណដែលតែងប្រារព្ធឡើងនៅអំឡុងថ្ងៃទី៣ ខែកុម្ភៈ ដើម្បីបណ្ដេញឧបទ្រពចង្រៃ និងជាពេលចាប់ផ្ដើមរដូវផ្ការីក។ សមាជិកគ្រួសារម្នាក់ ពាក់របាំងមុខដែលតំណាងជាតួបីសាចឬយក្ខ (អូនី) ហើយសមាជិកដទៃទៀតបាចសណ្ដែកសៀងសំដៅទៅយក្ខនោះឲ្យរត់ចេញពីផ្ទះ។



### សូហ្គាត់ស៊ឹ(ថ្ងៃបុណ្យចូលឆ្នាំ) (ថ្ងៃទី១ ខែមករា)

ក្រុមហ៊ុន និងហាងទំនិញជាច្រើនឈប់សម្រាកបុណ្យចូលឆ្នាំរហូតដល់ថ្ងៃទី៣ ខែមករា។ គ្រួសារជប៉ុនប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីដោយមានរៀបចំអាហារពិសេស( មើលរូប) និងមានទំនៀមទម្លាប់បួងសួងសូមឲ្យមានសុខភាពល្អ និងសុភមង្គល។



### តាណាបាតា(ពិធីបុណ្យផ្កាយ) (ថ្ងៃទី៧ ខែកក្កដា)

ថ្ងៃទី៧ ខែកក្កដា ប្រជាជនជប៉ុនតែងសរសេរបំណងប្រាថ្នារបស់ខ្លួននៅលើចម្រៀកក្រដាសពណ៌ ហើយចងព្យួរទៅនឹងមែកឫស្សីដែលគេតុបតែងនៅតាមផ្លូវក្នុងពិធីបុណ្យ។ នៅតំបន់ខ្លះគេប្រារព្ធពិធីបុណ្យតាណាបាតានៅខែសីហា។






### ពិធីបាញ់កាំជ្រួច (ពាក់កណ្ដាលខែសីហា)

ប្រទេសជប៉ុនល្បីល្បាញទៅលើពិធីបាញ់កាំជ្រួចដ៏ធំនៅពាក់កណ្ដាលខែសីហា ដែលប្រារព្ធឡើងជាពិសេសនៅតាមច្រាំងទន្លេ ឬឆ្នេរសមុទ្រតាមតំបន់នីមួយៗ។ ព្រឹត្តិការណ៍បាញ់កាំជ្រួចធំជាងគេគឺមានរយៈពេលមួយម៉ោង ហើយពោរពេញទៅដោយពន្លឺចម្រុះពណ៌ជាង៥០០០ពណ៌ពាសពេញផ្ទៃមេឃ។

### ត្សឹគីមិ(បុណ្យសែនព្រះខែ) (ពាក់កណ្ដាលខែកញ្ញា)

ព្រះច័ន្ទពេញវង់ដែលស្រស់ស្អាតជាងគេគឺនៅរដូវស្លឹកឈើជ្រុះ ហើយប្រជាជនទាំងអស់បានជួបជុំគ្នារៀបចំពិធីជប់លៀងរីករាយជាមួយពន្លឺព្រះច័ន្ទហើយមានការតុបតែងលម្អដោយស្មៅម្យ៉ាងស្រដៀង នឹងដើមត្រែង និងសែននំធ្វើពីម្សៅអង្ករដំណើបដែលមានរូបរាងដូចព្រះច័ន្ទពេញវង់។







### ពិធីបុណ្យរដូវស្លឹកឈើជ្រុះ (ខែវិច្ឆិកា)

រដូវស្លឹកឈើជ្រុះគឺជាពេលវេលាប្រមូលផលដំណាំ ហើយប្រជាជនជប៉ុនទាំងអស់រៀបចំពិធីបុណ្យថ្លែងអំណរគុណសម្រាប់គ្រាប់ពូជដំណាំប្រចាំឆ្នាំ។ ប្រជាជនគ្រប់សហគមន៍នាំគ្នាដង្ហែរអារក្ខប្រចាំតំបន់របស់ពួកគេនៅជុំវិញកន្លែងពួកគេរស់នៅ និងសែងវត្ថុជាទីសក្ការៈរបស់ពួកគេក្នុងគ្រែស្នែង(មិកូស៊ិ)។

# ភូមិសាស្ត្រ និង ធម្មជាតិ

ប្រទេសជប៉ុនមាន៤៧ ខេត្ត។ ផ្អែកតាមមូលដ្ឋានភូមិសាស្ត្រ និងប្រវត្តិសាស្ត្រ ខេត្តទាំងនេះត្រូវបានចែកចេញជា៩តំបន់គឺ ហុកកៃដូ តូហូគុ កានតូ ជូប៊ុ គីនគី ជូហ្គូគុ ស៊ីកូគុ គ្យូស្យ៊ូ និងអូគីណាវ៉ា។ តំបន់នីមួយៗមានគ្រាមភាសា និងទំនៀមទំលាប់ផ្សេងៗ ព្រមទាំងវប្បធម៌ ប្រពៃណីដែលមានលក្ខណៈពិសេសតាមតំបន់។ រាជធានីតូក្យូគឺជាមជ្ឈមណ្ឌលរបស់ប្រទេសជប៉ុន ហើយទីក្រុងសំខាន់ៗដទៃទៀត បំពេញតួនាទីជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច វប្បធម៌ ទៅតាមតំបន់នីមួយៗរបស់ខ្លួន។

## ហ៊ីរ៉ូស៊ីម៉ា Hiroshima

នៅឆ្នាំ១៩៤៥ ហ៊ីរ៉ូស៊ីម៉ាបានក្លាយជាទីក្រុងដំបូងបំផុតនៅលើពិភពលោកដែលទទួលរងការទម្លាក់គ្រាប់បែកបរមាណូ ប៉ុន្តែត្រូវបានស្តារឡើងវិញរហូតក្លាយជាទីក្រុងដ៏សំខាន់មួយរបស់ប្រទេសជប៉ុន។



© SAN/a.collectionRF/amanaimages

## ហ្វ៊ូគូអូកា Fukuoka

ជាទីក្រុងធំបំផុតក្នុងតំបន់គ្យូស្យ៊ូ។ ហ្វ៊ូគូអូកាមានភូមិសាស្ត្រនៅជិតទ្វីបអាស៊ីដីគោក និងជាមជ្ឈមណ្ឌលនៃការផ្លាស់ប្តូរគ្នារវាងប្រទេសជប៉ុន និងប្រទេសផ្សេងទៀតនៅទ្វីបអាស៊ី។ ហ្វ៊ូគូអូកាជាម្ចាស់ផ្ទះក្នុងពីធីបុណ្យប្រពៃណីជាច្រើនដូចជាហាកាតាដុនតាគុ ហើយជាម្ចាស់នៃម្ហូបអាហារដ៏ល្បីល្បាញដូចជាមីស៊ូតាគី (ស៊ុបមាន់ក្តៅ) និង មីរ៉ាមែន។ នៅតាមមាត់ទន្លេមានតូបលក់អាហារដែលជាទីកន្លែងមួយទាក់ទាញភ្ញៀវទេសចរ។



©GYRO PHOTOGRAPHY/a.collectionRF/amanaimages

## ណាហា Naha

ជាទីក្រុងធំបំផុតនៃខេត្តអូគីណាវ៉ាដែលជាខេត្តស្ថិតនៅចុងខាងត្បូង ឈៀងខាងលិចបំផុតនៃប្រទេសជប៉ុន។ អូគីណាវ៉ា លាតសន្ធឹងទៅភាគនិរតីនៃតំបន់គ្យូស្យ៊ូមាន១៦០កោះ ហើយមានអាកាសធាតុត្រូពិចប្រកបដោយធម្មជាតិដ៏ស្រស់ត្រកាល និងមានអាកាសធាតុក្តៅល្មម។ មហាសាគរដ៏ខៀវស្រងាត់បានធ្វើឲ្យកោះទាំងឡាយក្លាយជាទីកន្លែងដ៏ល្អបំផុតក្នុងពិភពលោកសម្រាប់កីឡាមុជទឹកមើលបាតសមុទ្រ និងសកម្មភាពកម្សាន្តផ្សេងៗនៅសមុទ្រ។



©BUD international/amanaimages



## ក្យូតូ Kyoto

ជារាជធានីរបស់ប្រទេសជប៉ុនកាលពីចុងសតវត្សទី៨ ត្រូវបានស្គាល់ថាជាទីក្រុងដែលមានវត្តបុរាណ និងសួនស្រស់ស្អាត។ នៅឆ្នាំ១៩៩៤ អង្គការយូណេស្កូបានបញ្ចូលវត្ត ព្រះវិហារ និងប្រាសាទផ្សេងៗចំនួន ១៧ នៅទីក្រុងក្យូតុ ទីក្រុងអ៊ូជិ និងទីក្រុងអូតស៊ឹ ជាបេតិកភណ្ឌពិភពលោក។



© JP/amanaimages




## អូសាកា Osaka

ជាទីក្រុងដ៏ធំបំផុតទីពីរបន្ទាប់ពីទីក្រុងតូក្យូ និងល្បីល្បាញដោយសារអាហារដ៏មានឱជារស និងរឿងកំប្លែង។ នៅឆ្នាំ១៩៩៤ អាកាសយានដ្ឋានអន្តរជាតិកានសៃបានបើកដំណើរការលើកោះសិប្បនិម្មិតនៅឈូងសមុទ្រអូសាកា។



© GYRO PHOTOGRAPHY/a.collectionRF/amanaimages

## សាប់ប៉ូរ៉ូ Sapporo

ជាទីក្រុងធំជាងគេបង្អស់នៅតំបន់ហុកកៃដូ។ ទីក្រុងនេះបានអភិវឌ្ឍឡើងតាមការរចនាប្លង់នៅចុងសតវត្សទី១៩ ហើយមហាវិថីទាំងឡាយនៃទីក្រុងត្រូវបានរចនាយ៉ាងមានរបៀប។



© GYRO PHOTOGRAPHY/a.collectionRF/amanaimages

## តូក្យូ Tokyo

ជាមជ្ឈមណ្ឌលនយោបាយរបស់ប្រទេសជប៉ុនតាំងពីឆ្នាំ១៦០៣ ជារាជធានី និងជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងព័ត៌មានរបស់ជាតិ។ ស្ថិតនៅចំកណ្ដាលទីក្រុងមានព្រះរាជវាំងព្រះចៅអធិរាជ ហើយនៅជុំវិញព្រះរាជវាំងមានអគារ សភាជាតិ ក្រសួងនានា និងតំបន់ពាណិជ្ជកម្ម។



© PHOTOLIFE/a.collectionRF/amanaimages

## ណាហ្គូយ៉ា Nagoya

ជាទីក្រុងធំបំផុតក្នុងតំបន់ជូប៊ុ។ តំបន់ជុំវិញទីក្រុងណាហ្គូយ៉ាគឺជាមជ្ឈមណ្ឌលដែលមានការរីកចម្រើនខ្លាំងបំផុតផ្នែកផលិតកម្មរថយន្ត និងឧស្សាហកម្មផ្សេងៗទៀត។ ប្រាសាទណាហ្គូយ៉ាដែលជានិមិត្តរូបរបស់ទីក្រុងត្រូវបានកសាងឡើងក្នុងឆ្នាំ១៦១២ ដោយលោក តូគូហ្គាវ៉ា អ៊ីអេយ៉ាស៊ូជាប្រមុខរដ្ឋាភិបាលអេដូ។ ត្រកូលតូគូហ្គាវ៉ានេះបានគ្រប់គ្រងប្រទេសជប៉ុនអស់រយៈពេលជាង២៦០ឆ្នាំ។ ប្រាសាទនេះល្បីល្បាញដោយសារមានរូបចម្លាក់សាជីហូកុមាសពីរ (សត្វសមុទ្រកើតតាមមនោគតិ) នៅលើដំបូល។



© Akaishizawa Takehiko/a.collectionRF/amanaimages

# លំនៅស្ថាន អាហារ និងសម្លៀកបំពាក់

របៀបនៃការរស់នៅបច្ចុប្បន្នរបស់ប្រជាជនជប៉ុនគឺបែបបុរាណ និងទំនើបច្របាច់បញ្ចូលគ្នា។ យើងអាចឃើញដូចរូបភាពខាងក្រោមនេះ នូវអាហារដែលប្រជាជនជប៉ុនទទួលទាន លំនៅស្ថានដែលគេរស់នៅ និងសម្លៀកបំពាក់របស់ពួកគេ។












ក្មេងៗកំពុងដោះស្បែកជើងនៅច្រកចូលផ្ទះ



កុមារកំពុងរៀន

### លំនៅស្ថានជប៉ុន

លំនៅស្ថានបែបប្រពៃណីជប៉ុន គឺត្រូវអង្គុយផ្ទាល់នឹងតាតាមិ (កន្ទេលជប៉ុន)។ បន្ទប់បែបជប៉ុនដដែលក៏អាចប្រែក្លាយទៅជាបន្ទប់ទទួលទានអាហារ ឬបន្ទប់គេងដោយគ្រាន់តែបន្ថែមហ្វូតុន (ពូកទ្រនាប់ជប៉ុន) ប៉ុណ្ណោះ។ ចំពោះលំនៅស្ថានបែបទំនើបវិញគឺតែងតែមានទាំងបន្ទប់បែបជប៉ុនដែលប្រើតាតាមិ និងបន្ទប់បែបបស្ចិមប្រទេស។ ទោះបែបណាក៏ដោយតាមទំនៀមទំលាប់ប្រជាជនជប៉ុនគឺនៅតែដោះស្បែកជើងនៅមាត់ទ្វារផ្ទះ។














## គីម៉ូណូ

កាលពីសម័យមុន ប្រជាជនជប៉ុនតែងស្លៀកគីម៉ូណូគ្រប់ពេលទាំងអស់។ ប៉ុន្តែបច្ចុប្បន្ន ពួកគាត់តែងស្លៀកសម្លៀកបំពាក់បែបបស្ចិមប្រទេស ដោយបន្តស្លៀកគីម៉ូណូសម្រាប់តែព្រឹត្តិការណ៍ពិសេស ពិធីបុណ្យផ្សេងៗ និងនៅក្នុងសកម្មភាពវប្បធម៌មួយចំនួន ដូចជានៅពេលរាំរបាំជប៉ុន កិច្ចតុបតែងផ្កា និងពិធីលៀងតែជាដើម។









យើងប្រើចង្កឹះដើម្បីទទួលទានបាយក្នុងចានចង្កឹះ

## អាហារជប៉ុន

ប្រភេទអាហារដែលទទួលទាននៅផ្ទះ (រូបខាងក្រោមផ្នែកខាងស្តាំ) ចែកជាបីផ្នែកគឺ បាយចានចង្កឹះ ទឹកស៊ុបមីសុ និងម្ហូបផ្សេងៗ។ ចំពោះស៊ូស៊ី (រូបខាងលើ) និង ថេមភូរ៉ា (រូបខាងក្រោមផ្នែកខាងឆ្វេង) គឺពេញនិយមសម្រាប់មនុស្សគ្រប់វ័យ។ សម្រាប់អាហារសម្រន់ យើងតែងតែបរិភោគបាយពូត អូនីហ្គីរី (រូបភាពគំនូរខាងស្តាំ)។



# ការអប់រំ

## សាលារៀន

ប្រព័ន្ធអប់រំជាមូលដ្ឋាននៅប្រទេសជប៉ុនមានសាលាបឋមសិក្សា(ប្រាំមួយឆ្នាំ) អនុវិទ្យាល័យ(បីឆ្នាំ) វិទ្យាល័យ(បីឆ្នាំ) និងមហាវិទ្យាល័យ(បួនឆ្នាំ)។

កាតព្វកិច្ចសិក្សាដែលខានមិនបានមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញជប៉ុនគឺសិក្សារយៈពេល៩ឆ្នាំ គឺនៅបឋមសិក្សា និងអនុវិទ្យាល័យ ប៉ុន្តែសិស្ស៩៨%បន្តការសិក្សាដល់កម្រិតវិទ្យាល័យ។ ជាធម្មតាសិស្សត្រូវតែប្រឡងដើម្បីចូលរៀននៅវិទ្យាល័យ និងមហាវិទ្យាល័យ។

កុមារជប៉ុនចូលរៀនថ្នាក់ទី១ បន្ទាប់ពីខួបកំណើតគម្រប់អាយុប្រាំមួយឆ្នាំរបស់ពួកគេ។ ជាទូទៅការបើកបវេសនកាលជប៉ុនធ្វើឡើងនៅដើមខែមេសា។

### ប្រព័ន្ធអប់រំ




## សកម្មភាពនៅសាលារៀន



សកម្មភាពសិស្សប្រគំតន្ត្រី



សកម្មភាពកូនសិស្សតូចៗសម្អាត់ថ្នាក់រៀន

នៅក្នុងសាលាបឋមសិក្សាជប៉ុន ថ្នាក់រៀននីមួយៗចែកជាក្រុមតូចៗសម្រាប់ធ្វើសកម្មភាពច្រើនយ៉ាង ដូចជាក្រុមសម្អាតទីធ្លាសាលា សាលធំៗ បន្ទប់រៀន និងបន្ទប់ទឹកជាដើម។ ពេលថ្ងៃត្រង់មានការទទួលទានអាហារ សិស្សានុសិស្សដាក់វេនគ្នា មានក្រុមបម្រើសេវាកម្មជាដើម។ អាហារថ្ងៃត្រង់របស់សាលាសម្បូរដោយអាហារដែលមានជីវជាតិល្អសម្រាប់ការលូតលាស់របស់កុមារ។

សម្រាប់អនុវិទ្យាល័យទៅសាលានីមួយៗមានក្លឹបផ្សេងៗជាច្រើនដូចជា ក្លឹបតន្ត្រី ឬសិល្បៈ ក្លឹបវិទ្យាសាស្ត្រ ក្លឹបកីឡា មានដូចជា កីឡាយូដូ ការ៉ាតេដូ កេនដូ កីឡាបាល់ទាត់ និងកីឡាបេសប៊ល ដែលពេញនិយមបំផុតសម្រាប់ក្មេងប្រុស។

សាលារៀននីមួយៗតែងមានរៀបចំព្រឹត្តិការណ៍ប្រចាំឆ្នាំ ដូចជាទិវាកីឡាដែលសិស្សានុសិស្សប្រកួតទាញព្រ័ត្រ រត់បណ្ដាក់ ការសម្តែងរបាំ វប្បធម៌ផ្សេងៗ និងមានដំណើរកម្សាន្តទៅកាន់កន្លែងប្រវត្តិសាស្ត្រនានា។

## ភាសាជប៉ុន

តួអក្សរជប៉ុនមាន៣ប្រភេទគឺ កាន់ជិ ហ៊ីរ៉ាហ្គាណា និង កាតាកាណា។ តួអក្សរកាន់ជិត្រូវបាននាំចូលពីប្រទេសចិនក្នុងទសវត្សទី៥ ហើយក្រោយមកតួអក្សរមួយចំនួនក៏ត្រូវបានប្រើដើម្បីបង្កើតបានជាតួអក្សរ ហ៊ីរ៉ាហ្គាណា និង កាតាកាណា។




## កាន់ជិ

អក្សរកាន់ជិបូរាណកើតពីរូបភាពតូចៗដែលបង្ហាញពីអត្ថន័យនៃពាក្យនីមួយៗ ប៉ុន្តែសព្វថ្ងៃអក្សរកាន់ជិមិនដូចកាលពីសម័យបុរាណទេ។ យើងអាចអានភាសាជប៉ុននៅសម័យទំនើបនេះបានដោយគ្រាន់តែយើងបានរៀនពីតួអក្សរកាន់ជិប្រមាណ២០០០តួប៉ុណ្ណោះ។







## តារាងតួអក្សរ ហ៊ីរ៉ាហ្គាណា និង កាតាកាណា

សម្លេងភាសាជប៉ុនអាចសរសេរបាន៤៦តួអក្សរ និងបូកបន្ថែមនូវតួអក្សរផ្សំផ្សេងៗទៀត នាំឲ្យការបញ្ចេញសម្លេងប្រែប្រួលបន្តិចបន្តួច (ឧទាហរណ៍ សម្លេង កា ទៅជា ហ្គា )។ ទាំងតួអក្សរហ៊ីរ៉ាហ្គាណា និងកាតាកាណា សម្លេងព្យញ្ជនៈ គឺតែងតែផ្សំជាមួយសម្លេងស្រៈ។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| あ ア a | か カ ka | さ サ sa | た タ ta | な ナ na | は ハ ha | ま マ ma | や ヤ ya | ら ラ ra | わ ワ wa | |
| い イ i | き キ ki | し シ shi | ち チ chi | に ニ ni | ひ ヒ hi | み ミ mi | | り リ ri | | |
| う ウ u | く ク ku | す ス su | つ ツ tsu | ぬ ヌ nu | ふ フ fu | む ム mu | ゆ ユ yu | る ル ru | | |
| え エ e | け ケ ke | せ セ se | て テ te | ね ネ ne | へ ヘ he | め メ me | | れ レ re | | |
| お オ o | こ コ ko | そ ソ so | と ト to | の ノ no | ほ ホ ho | も モ mo | よ ヨ yo | ろ ロ ro | を ヲ wo | ん ン n |

| | | | | |
|---|---|---|---|---|
| が ガ ga | ざ ザ za | だ ダ da | ば バ ba | ぱ パ pa |
| ぎ ギ gi | じ ジ ji | ぢ ヂ ji | び ビ bi | ぴ ピ pi |
| ぐ グ gu | ず ズ zu | づ ヅ zu | ぶ ブ bu | ぷ プ pu |
| げ ゲ ge | ぜ ゼ ze | で デ de | べ ベ be | ぺ ペ pe |
| ご ゴ go | ぞ ゾ zo | ど ド do | ぼ ボ bo | ぽ ポ po |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| きゃ キャ kya | しゃ シャ sha | ちゃ チャ cha | にゃ ニャ nya | ひゃ ヒャ hya | みゃ ミャ mya | りゃ リャ rya | ぎゃ ギャ gya | じゃ ジャ ja | びゃ ビャ bya | ぴゃ ピャ pya |
| きゅ キュ kyu | しゅ シュ shu | ちゅ チュ chu | にゅ ニュ nyu | ひゅ ヒュ hyu | みゅ ミュ myu | りゅ リュ ryu | ぎゅ ギュ gyu | じゅ ジュ ju | びゅ ビュ byu | ぴゅ ピュ pyu |
| きょ キョ kyo | しょ ショ sho | ちょ チョ cho | にょ ニョ nyo | ひょ ヒョ hyo | みょ ミョ myo | りょ リョ ryo | ぎょ ギョ gyo | じょ ジョ jo | びょ ビョ byo | ぴょ ピョ pyo |

あ = Hiragana
ア = Katakana
a = English reading



# ប្រវត្តិសាស្ត្រ

## ព្រឹត្តិការណ៍សំខាន់ៗ នៃប្រទេសជប៉ុន

### ចាប់ពីសម័យកាលបរបាញ់មកដល់សម័យកាលដាំដុះដំណាំស្រូវ

- សម័យកាលថ្ម — ប្រជាជនរស់នៅដោយការបរបាញ់ និងប្រមូលផល
- យុគសម័យចូម៉ុន — ការតាំងលំនៅស្ថានជាអចិន្ត្រៃយ៍ចាប់ផ្តើម ប្រជាជនប្រើឧបករណ៍ថ្មរំលីង និងកុម្ភការភ័ណ្ឌ(ឆ្នាំង ក្រឡ...ធ្វើពីដីឥដ្ឋ)
- យុគសម័យយ៉ាយ៉ូអ៊ី — ការចាប់ផ្តើមដាំដុះដាំណាំស្រូវ និងឧបករណ៍ធ្វើអំពីលោហធាតុ
- សតវត្សទី៤-៥ — ឯកភាពវប្បនិយកម្មនៃតុលាការយ៉ាម៉ូតុត្រូវបានធ្វើឡើង *ទីបញ្ចុះសពសាងសង់ជុំវិញប្រទេស *ព្រះពុទ្ធសាសនា *អក្សរចិន *បច្ចេកវិទ្យាថ្មី និងវប្បធម៌ដទៃទៀតត្រូវបាននាំចូលមកប្រទេសជប៉ុនពីទីបផ្សេងៗ

### សម័យកាលនៃការស្ថាបនាទីក្រុង និងអភិជនភាព

- ៥៩៣ — ព្រះអង្គម្ចាស់ សូតូគុ ក្លាយជារាជានុសិទ្ធិ
- ៧១០ — រាជធានី ដូរមកនៅណារ៉ា
- ៧៥២ — ព្រះពុទ្ធបដិមាដ៏ធំនៅឯវិហារតូដាអ៊ិជិ ត្រូវបានស្ថាបនាចប់សព្វគ្រប់
- ៧៩៤ — រាជធានី ដូរមកនៅក្យូតូ អភិជនភាពកាន់តែមានឥទ្ធិពលការប្រើអក្សរជប៉ុនកាណាបានចាប់ផ្តើម ហ្គេនជិ ម៉ូណូហ្កាតារិ (រឿងនិទានរបស់ហ្គេនជិ) ប្រលោមលោកដែលចាស់ជាងគេបំផុតក្នុងលោកត្រូវបាននិពន្ធដោយលោក ម៉ូរ៉ាសាគី ស៊ីគីប៊ុ


រូបគំនូរពីរឿង ហ្គេនជិ ម៉ូណូហ្កាតារិ

### ពីសម័យកាលអភិជនភាពមកសម័យកាលសឹកសង្គ្រាម

- ១១៩២ — មីណាម៉ូតុ ណូ យ៉ូរីតូម៉ូ បង្កើតរបបកាម៉ាគូរ៉ា
- ១២៧៤ — ពួកម៉ុងហ្គោលវាយប្រហារជប៉ុន (និងម្តងទៀតក្នុងឆ្នាំ១២៨១)
- ១៣៣៦ — អាស៊ីកាហ្កា តាកាអ៊ូជិ បង្កើតរបប មូរ៉ូម៉ាជិ (ក្យូតូ)
- ១៤៨៩ — សង្គ្រាមរវាងវណ្ណៈអភិជនសក្តិភូមិបានរាលដាលទូទាំងប្រទេស
- ១៥៤៣ — ជនជាតិព័រទុយហ្គាល់នាំកាំភ្លើងចូលមកប្រទេសជប៉ុនដំបូងគេបំផុត
- ១៥៤៩ — គ្រិស្តសាសនាត្រូវបាននាំមកប្រទេសជប៉ុនដោយលោក Francis Xavier
- ១៥៩០ — តូយ៉ូតូមិ ហ៊ីដេយ៉ូស៊ិ បង្រួបបង្រួមប្រទេសជប៉ុន


ប្រាសាទ ហ៊ីមេជិ

### ពីសម័យកាលសង្គ្រាមមកសម័យកាលជំនួញ

- ១៦០៣ — តូគុហ្កាវ៉ា អ៊ីអេយ៉ាស៊ូ បង្កើតរបប អេដូ ឈ្មួញកាន់តែមានឥទ្ធិពលខ្លាំងក្លាខណៈដែលពាណិជ្ជកម្មរីកចម្រើន
- ១៦៣៩ — ជប៉ុនកាត់ផ្តាច់ទំនាក់ទំនងជាមួយពិភពលោកទាំងស្រុង

ចំនួនសាលារៀនតាមវិហារបានកើនឡើង ការអានការសរសេរ ក្បាច់គិតលេខ សីលធម៌និងមុខវិជ្ជាផ្សេងៗទៀតត្រូវបានបង្ហាត់បង្រៀនយ៉ាងទូលំទូលាយ


ទស្សនីយភាព ហាងទំនិញ ម៉ាត់ស៊ូសាកាយ៉ា នៅឆ្នាំ១៧៦៨

- ១៨៥៣ — ឧត្តមនាវាត្រីអាមេរិកឈ្មោះ Mathew Perry មកដល់ Uraga ដើម្បីទាមទារឲ្យជប៉ុនបើកចំហជាមួយលោកខាងក្រៅ

## ព្រឹត្តិការណ៍សំខាន់ៗ ក្នុងពិភពលោក

| | |
|---|---|
| C.3500 BC | អារ្យធម៌លើកដំបូងរីកចម្រើននៅមេសូប៉ូតាមៀ |
| C.3000 BC | រដ្ឋឯកភាពបានកើតឡើងនៅអេហ្ស៊ីប |
| C.2500 BC | អារ្យធម៌ឥណ្ឌបានកកើតនៅប្រទេសឥណ្ឌា |
| C.1760 BC | ក្រមច្បាប់ ហាំមូរ៉ាប៊ី ត្រូវបានបង្កើតនៅបេប៊ីឡូន៉ៀ |
| C.1400 BC | រាជវង្សយិនត្រូវបានបង្កើតឡើងក្នុងប្រទេសចិន |
| 116 | ចក្រភពរ៉ូម៉ាំងគ្រប់គ្រងតំបន់ធំបំផុត |
| 313 | គ្រីស្តសាសនាត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជាធិរាជ កុងស្តង់ទីនី |
| 589 | រាជវង្សស៊ូអ៊ិ បង្រួបបង្រួមប្រទេសចិន |
| 7th C | សាសនាឥស្លាមត្រូវបានបង្កើតឡើងដោយម៉ូហាមេដ |
| 800 | សាឡឺម៉ាញ មហាក្សត្រអំបូរហ្វ្រង់ក៍ត្រូវបានរាជាភិសេកជារាជាធិរាជរបស់ចក្រភពរ៉ូម៉ាំងខាងលិច |
| 962 | អុត្តូ ត្រូវបានរាជាភិសេកជារាជាធិរាជរបស់ចក្រភពរ៉ូម៉ាំងផ្អែកសាសនា |
| 1206 | ហ្គេនហ្គិសខាន់ បង្កើតចក្រភពម៉ុងហ្គោល |
| 1299 | ចក្រភពអុតូម៉ាន់ ត្រូវបានបង្កើតឡើង |
| 1337 | សង្គ្រាមរយឆ្នាំរវាងប្រទេសអង់គ្លេស និងប្រទេសបារាំងបានចាប់ផ្តើម |
| 1492 | គ្រីស្តូហ្វឺ កូឡុំប៊ីសរកឃើញទ្វីបអាមេរិក |

## ព្រឹត្តិការណ៍សំខាន់ៗ នៃប្រទេសជប៉ុន

### ជប៉ុន បើកចំហជាមួយលោកខាងក្រៅ

- ១៨៥៤ ជប៉ុន និងសហរដ្ឋអាមេរិកចុះសន្ធិសញ្ញាសន្តិភាព និងមិត្តភាពដោយបញ្ចប់នូវការផ្តាច់ខ្លួនរបស់ប្រទេសជប៉ុន
- ១៨៥៨ ចុះសន្ធិសញ្ញាពាណិជ្ជកម្មជាមួយប្រទេសនានា
- ១៨៦៧ របបអេដូដួលរលំ ហើយរាជាធិរាជក្លាយជាស្នូលនៃនយោបាយ
- ១៨៦៨ ការស្តារមេជិឡើងវិញបានដំណើរការ ហើយអេដូត្រូវដាក់ឈ្មោះថ្មីថាតូក្យូ ការប្រែប្រួលដ៏ធំធេងខាងប្រព័ន្ធនយោបាយ សង្គម និងបែបផែននៃជីវភាពរស់នៅ ប្រព័ន្ធអប់រំដោយខានមិនបានត្រូវបានបង្កើតឡើង ការសាងសង់សាលាបឋមសិក្សាចាប់ផ្តើមទូទាំងប្រទេស
- ១៨៨៩ ច្បាប់រដ្ឋធម្មនុញ្ញរបស់រាជាណាចក្រជប៉ុនត្រូវចេញផ្សាយ
- ១៨៩០ សភារាជាធិរាជជប៉ុនចាប់ផ្តើមកិច្ចប្រជុំលើកទីមួយ
- ១៨៩៤-៩៥ សង្គ្រាមរវាងជប៉ុន និងចិន ឧស្សាហកម្មសូត្ររីកចម្រើន
- ១៩០៤-០៥ សង្គ្រាមរវាងជប៉ុន និងរុស្ស៊ី
- ១៩១៤-១៨ សង្គ្រាមលោកលើកទី១ ឧស្សាហកម្មធុនធ្ងន់រីកចម្រើន
- ១៩២៣ រញ្ជួយដីដ៏ធំនៅកាន់តូ
- ១៩២៥ ការបោះឆ្នោតបុរសជាសកលត្រូវបានដាក់ឲ្យអនុវត្ត
- ១៩៤១-៤៥ សង្គ្រាមនៅតំបន់មហាសមុទ្រប៉ាស៊ីហ្វិក
- ១៩៤៥ ការទម្លាក់គ្រាប់បែកបរមាណូលើទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្កាសាគី



សាលារៀនកៃជិ ជាសាលារៀនមួយដែលចាស់ជាងគេបំផុតនៅប្រទេសជប៉ុន

### ឆ្ពោះទៅកាន់ប្រទេសជប៉ុនមួយថ្មីក្រោយពេលសង្គ្រាម



ទេសភាពទីក្រុងដូចនេះ គឺជានិមិត្តរូបនៃការអភិវឌ្ឍរបស់ជប៉ុនក្រោយពេលសង្គ្រាម

- ១៩៤៦ ច្បាប់រដ្ឋធម្មនុញ្ញជប៉ុន ត្រូវបានបោះផ្សាយ កំណែទម្រង់សង្គមត្រូវបានអនុវត្ត
- ១៩៤៩ យូកាវ៉ា ហ៊ីដេគី ក្លាយជាពលរដ្ឋជប៉ុនដំបូងគេដែលទទួលរង្វាន់ណូបែលខាងរូបវិទ្យា
- ១៩៥១ សន្ធិសញ្ញាសន្តិភាពត្រូវចុះជាមួយប្រទេសផ្សេងៗ
- ១៩៥៦ ជប៉ុនក្លាយជាសមាជិករបស់អង្គការសហប្រជាជាតិ សេដ្ឋកិច្ចរីកលូតលាស់
- ១៩៦៤ ការប្រកួតកីឡាអូឡាំពិកប្រារព្ធនៅទីក្រុងតូក្យូជាកីឡាអូឡាំពិកដំបូងបំផុតនៅអាស៊ី តូកៃដូ ស៊ិនកានសេន(រថភ្លើងល្បឿន)ចាប់ផ្តើមដំណើរការ
- ១៩៧០ ការតាំងពិព័រណ៌ពិភពលោកនៅអូសាកាជា EXPO ទីមួយនៅអាស៊ី
- ១៩៧២ អូគីណាវ៉ា ត្រូវបានប្រគល់ឲ្យជប៉ុនវិញ ការប្រកួតកីឡាអូឡាំពិករដូវរងារធ្វើនៅទីក្រុងសាប់ប៉ូរ៉ូ
- ១៩៩៥ រញ្ជួយផែនដីដ៏ធំនៅ ហានស៊ិន-អាវ៉ាជិ
- ១៩៩៨ ការប្រកួតកីឡាអូឡាំពិករដូវរងារធ្វើនៅទីក្រុងណាហ្គាណូ
- ២០០២ FIFA World Cup ត្រូវបានធ្វើជាម្ចាស់ផ្ទះដោយជប៉ុន និងសាធារណរដ្ឋកូរ៉េ
- ២០០៤ រញ្ជួយផែនដីនៅ នីអ៊ីហ្កាតា-ជូអិតស៊ឺ
- ២០០៥ ការតាំងពិព័រណ៌ពិភពលោកនៅ អាអ៊ិជិ ស្តីអំពី "គតិបណ្ឌិតរបស់ធម្មជាតិ"
- ២០១១ ការរញ្ជួយដីដ៏ធំបំផុតនៅភាគខាងកើតនៃប្រទេសជប៉ុន ក្រុមបាល់ទាត់នារីនៃប្រទេសជប៉ុនបាននទទួលជ័យជំនះនៅក្នុងការប្រកួតបាល់ទាត់ពិភពលោក (FIFA WORLD CUP)

## ព្រឹត្តិការណ៍សំខាន់ៗ ក្នុងពិភពលោក

| | |
|---|---|
| 1600 | អង់គ្លេសបង្កើតក្រុមហ៊ុន East India ប្រទេសមហាអំណាចរបស់អឺរ៉ុបដាក់តំបន់ភាគច្រើននៃពិភពលោកជាអាណានិគម |
| C.1750 | បដិវត្តន៍ឧស្សាហកម្មចាប់ផ្តើមនៅអឺរ៉ុប |
| 1776 | ប្រទេសអាមេរិកប្រកាសឯករាជ្យ |
| 1789 | បដិវត្តន៍បារាំងចាប់ផ្តើម និងសេចក្តីប្រកាសសិទ្ធិមនុស្សត្រូវបានចេញផ្សាយ |
| 1876 | Alexander Graham Bell បង្កើតទូរស័ព្ទ |
| 1886 | Karl Benz បង្កើតរថយន្តដើរដោយប្រេងសាំង |
| 1930 | Orville nig Wilbur Wright ធ្វើដំណើរតាមយន្តហោះជាលើកដំបូង |
| 1914-18 | សង្គ្រាមលោកលើកទីI |
| 1929 | ដំណើរសេដ្ឋកិច្ចធ្លាក់ចុះដុនដាប់ខ្លាំងបានចាប់ផ្តើម |
| 1939-45 | សង្គ្រាមលោកលើកទី II |
| 1945 | អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង |
| 1957 | សហភាពសូវៀតបង្ហោះ Sputnik ជាផ្កាយរណបទី១ ផលិតដោយមនុស្ស |
| 1961 | Yuri Gagarin នៃសហភាពសូវៀតក្លាយជាមនុស្សទីមួយដែលបានទៅដល់លំហអាកាស |
| 1969 | មនុស្សលោកបានទៅដល់ឋានព្រះច័ន្ទជាលើកដំបូង |
| 2004 | រលកស៊ូណាមិ ដ៏ធំនៅមហាសមុទ្រឥណ្ឌា |

# វប្បធម៌

វប្បធម៌ជប៉ុនតែងតែប្លែកមានតែមួយគ្មានពីរ គឺវប្បធម៌ប្រពៃណី ដូចជាល្ខោនកាប៊ូគី និងពិធីលៀងតែជាដើម ហើយវប្បធម៌ទំនើបមានរួមបញ្ចូលទាំងវីដេអូហ្គេម និងគំនូរជីវចល អានីមេ។



### ខាវ៉ៃអ៊ី (គួរឲ្យស្រឡាញ់)

យើងអាចនិយាយនូវអារម្មណ៍ថា ខាវ៉ៃអ៊ី (គួរឲ្យស្រឡាញ់) ទៅលើវប្បធម៌ប្រជាប្រិយរបស់ជប៉ុន។ យុវវ័យទូទាំងពិភពលោកដើរតាមម៉ូដខាវ៉ៃអ៊ី ពីប្រទេសជប៉ុន។




### អានីមេ

គ្មានអ្វីដែលគួរឲ្យរំភើប និងអស់សំណើចជាង អានីមេទេ។ តើលោកអ្នកបានជ្រាបទេថា ភាគច្រើននៃគំនូរជីវចលអានីមេ ដែលចាក់បញ្ចាំងនៅរោងភាពយន្ត ឬតាមកញ្ចក់ទូរទស្សន៍នៅជុំវិញពិភពលោកគឺមានប្រភពដើមពីសៀវភៅផ្លុក ម៉ាងហ្កា និង ហ្គេមរបស់ប្រទេសជប៉ុន?



### ហ្គេម

វីដេអូហ្គេមសប្បាយៗ ដែលយើងអាចលេងដោយខ្លួនឯង ឬជាមួយមិត្តភក្តិ និងក្រុមគ្រួសារគឺតែងតែប្រឌិតឡើង និងបង្កើតឡើងនៅប្រទេសជប៉ុន ហើយនៅពេលមានការប្រកាសវត្ថុថ្មីនោះគឺជាព័ត៌មានដ៏លេចធ្លោសម្រាប់អ្នកលេងហ្គេមនៅជុំវិញពិភពលោក។




### រូបតុក្កតា

ក្មេងៗជប៉ុន និងយុវវ័យ ក៏ជាអ្នកគាំទ្ររូបសត្វដ៏គួរឲ្យស្រឡាញ់ និងរូបតុក្កតាដែលចេញពីអានីមេ និងម៉ាងហ្គា ហើយយើងអាចឃើញរូបនេះនៅលើរបស់ផ្សេងៗដូចជា អាវយឺត សំបកស្លាគ្រាប់ជាដើម។



### ខារ៉ាអូខេ

តាមរយៈម៉ាស៊ីនខារ៉ាអូខេ យើងអាចក្លាយជាតារាប្រជាប្រិយ និងអ្នកចម្រៀងសម្រាប់សមាជិកគ្រួសារ ឬមិត្តភក្តិ។



### ខូសផ្លេ

ខូសផ្លេ ក្លាយមកពីពាក្យ សម្លៀកបំពាក់ និង លេង (Cos-play= costume+play)។ អ្នកគាំទ្រ អានីមេ តែងបង្កើតសម្លៀកបំពាក់ដ៏អស្ចារ្យរបស់ខ្លួន ហើយស្លៀកពាក់ត្រាប់តាមតួអង្គក្នុងរឿងដែលពួកគេស្រឡាញ់ពេញចិត្តនៅក្នុងកម្មវិធីពិសេសៗ និងព្រឹត្តិការណ៍ប្រជុំអ្នកខូសផ្លេជាដើម។
















### ល្ខោនណូ

ល្ខោនណូគឺប្រភេទល្ខោនបុរាណចំណាស់មួយរបស់ប្រទេសជប៉ុន។ សាច់រឿងរៀបរាប់ដោយតួអង្គជាច្រើនតុបតែងខ្លួននូវសម្លៀកបំពាក់ចម្រុះពណ៌ និងមានពាក់របាំងមុខ ហើយបន្លឺសម្លេងដោយការស្មូត និងតន្ត្រី។

### ម្រ័ក្សណ៍ខ្មុក(សម្ភារៈសម្រាប់ផ្ទុក ដូចជាចាន)

ម្រ័ក្សណ៍ខ្មុកជប៉ុនគឺល្បីល្បាញរហូតដល់ពាក្យបុរាណនៃភាសាអង់គ្លេសគឺ "Japan" មានន័យថា "ម្រ័ក្សខ្មុក"។ ម្រ័ក្សណ៍ខ្មុកនៃសម្ភារៈសម្រាប់ដាក់ម្ហូបអាហារតែងត្រូវបានប្រើប្រាស់ជាប្រចាំនៅក្នុងផ្ទះថែមទាំងត្រូវបានយកមកប្រើប្រាស់ដើម្បីបង្កើតនូវសោភ័ណភាព និងតម្លៃនៃកិច្ចការសិល្បៈផងដែរ។

### ស្ថាបត្យកម្មឈើ

អាគារបុរាណជប៉ុនត្រូវបានសាងសង់ពីឈើ និងប្រើប្រាស់បច្ចេកទេសពិសេសនៃការងារជាងឈើ។ រចនាសម្ព័ន្ធចាស់ៗរបស់ជប៉ុនត្រូវបានរក្សាការពារយ៉ាងយកចិត្តទុកដាក់រហូតមកដល់សព្វថ្ងៃ ហើយវត្តអារាមជប៉ុន គឺជាសំណង់ឈើបុរាណចំណាស់ជាងគេលើពិភពលោកដែលនៅមានវត្តមាននាពេលបច្ចុប្បន្ន។

### អ៊ីកេបាណា (សិល្បៈតុបតែងផ្កា)

ជាង៤០០ឆ្នាំហើយ អ៊ីកេបាណា នៅតែបង្រៀនយើងពីសារៈសំខាន់នៃធម្មជាតិ ជីវិត និងសោភ័ណភាព ដូចដែលយើងរៀនពីការរៀបចំតុបតែងផ្កាតាមរដូវដោយយោងតាមទស្សនៈមេរៀននៃអ៊ីកេបាណា។

### ល្ខោនកាប៊ូគិ

កាប៊ូគិ គឺជាល្ខោនម្យ៉ាងដែលបានវិវត្តក្នុងដើមសតវត្សរ៍ទី១៧ ហើយតួសម្តែងទាំងអស់សុទ្ធតែជាបុរស។ តួសម្តែងនិយាយក្នុងលក្ខណៈជាចង្វាក់ និងស្លៀកពាក់ដែលមានលក្ខណៈហ៊ឺហារបៀបផាត់មុខប្រផូ (គូម៉ាដូរី) និងការប្រើប្រាស់គ្រឿងម៉ាស៊ីនដើម្បីបង្កើតជាផ្ទៃឆាកដែលមានលក្ខណៈពិសេស។

### គំនូរអ៊ុគិយ៉ូអិ (គំនូរផ្ដិតចេញពីពុម្ពឈើ)

សិល្បករជប៉ុនបានអភិវឌ្ឍគំនូរផ្ដិតចេញពីពុម្ពឈើមានតែមួយនេះនៅទសវត្សរ៍ទី១៨។ ក្រោយពីសិល្បករអ៊ឺរ៉ុប បានរកឃើញគំនូរអ៊ុគិយ៉ូអិនេះហើយ គំនូរនេះត្រូវបានរីកសុះសាយយ៉ាងទូលំទូលាយនៅទស្សវត្សទី១៩ នៃអ្នកបារាំងនិយម។

# កីឡា

យើងលេងកីឡាជាច្រើនប្រភេទក្នុងប្រទេសជប៉ុន។ ក្បាច់គុណប្រពៃណីដូចជា យូដូ និងកេនដូ មានការពេញនិយមយ៉ាងខ្លាំង ហើយមានកីឡាដែលមានប្រភពពីបរទេសដូចជា បេសបិល និងបាល់ទាត់ក៏ពេញនិយមផងដែរ។





កីឡាស្គីបន្ទះឈើ



កីឡាស្ទូចត្រី

## ស៊ូម៉ូ

ស៊ូម៉ូជាប្រភេទកីឡាបោកចំបាប់ដែលមានអាយុជាង ១០០០ឆ្នាំហើយ។ កីឡាករស៊ូម៉ូ មិនស្លៀកសម្លៀកបំពាក់អ្វីច្រើនទេ គ្រាន់តែពាក់ខ្សែក្រវ៉ាត់ដ៏ធំ និងទុកម៉ូដសក់របស់ពួកគេដូចម៉ូដសម័យបុរាណ។



កីឡាបេសបិល





កីឡាជិះស្គីលើទឹកកក

## យូដូ

យូដូ សព្វថ្ងៃត្រូវបានចូលជាប្រភេទកីឡាអូឡាំពិក ហើយត្រូវបានស្គាល់ថាជាកីឡាប្រដាល់ជប៉ុន។ ដូចគ្នានឹងកីឡាប្រដាល់ជប៉ុនបុរាណដែរ កីឡាយូដូគឺបង្រៀនយើងឲ្យគោរពអ្នកដទៃ និងហ្វឹកហាត់ស្មារតីរបស់ខ្លួន។



កីឡាជិះក្ដារបន្ទះលើទឹករលក



កីឡាបាល់ទះ



កីឡាបាល់ទាត់



កីឡាវាយកូនហ្គោល



កីឡារត់ប្រណាំង



## គ្យូដូ

គ្យូដូ គឺជាកីឡាបាញ់ធ្នូបែបបុរាណដោយប្រើធ្នូប្រពៃណីពិសេសកីឡានេះល្បីល្បាញដោយសាររៀនពីការផ្ចង់អារម្មណ៍ និងកំលាំង។ មិនតែប៉ុណ្ណោះកីឡានេះក៏មានការប្រកួតបាញ់ធ្នូនៅលើខ្នងសេះផងដែរ។



## កេនដូ

កេនដូបានចាប់ផ្ដើមដូចប្រព័ន្ធហ្វឹកហាត់សម្រាប់សាម៉ូរ៉ៃ ដើម្បីអនុវត្តបច្ចេកទេសប្រយុទ្ធផ្លែដាវរបស់ពួកគេ។ នៅពេលហ្វឹកហាត់យើងប្រើដាវឬស្សី និងស្លៀកសំលៀកបំពាក់ការពារខ្លួន។



## ការ៉ាតេ

ការ៉ាតេមានដើមកំណើតនៅខេត្តអូគីណាវ៉ា ដែលស្ថិតនៅផ្នែកខាងត្បូងបង្អស់នៃប្រទេសជប៉ុន។ កីឡាករការ៉ាតេហ្វឹកហាត់បច្ចេកទេសវាយ និងទាត់ដោយអនុវត្តនូវចលនាជាបន្តបន្ទាប់ដែលហៅថាកាតា(ក្បាច់)។

# ព្រះរាជវង្សានុវង្ស

តាមច្បាប់រដ្ឋធម្មនុញ្ញជប៉ុន ព្រះចៅអធិរាជជានិមិត្តរូបរបស់ជាតិ និងឯកភាពរបស់ប្រជាជន។ ព្រះអង្គគ្មានអំណាចអ្វីទាក់ទងទៅនឹងរដ្ឋាភិបាលទេ។ ព្រះករុណា ព្រះចៅអធិរាជ អាគីហ៊ីតូ បានឡើងគ្រងរាជ្យជាព្រះចៅអធិរាជទី១២៥របស់ជប៉ុន ពីឆ្នាំ១៩៨៩។

សមាជិកព្រះរាជវង្សានុវង្សទទួលភ្ញៀវរដ្ឋមកពីប្រទេសផ្សេងៗ ហើយធ្វើទស្សនកិច្ចទៅបរទេស។ តាមរយៈសកម្មភាពទាំងនេះ សមាជិករាជវង្សានុវង្សបំពេញតួនាទីដ៏សំខាន់ក្នុងការជួយធ្វើឲ្យប្រសើរឡើងនូវចំណងមិត្តភាពជាអន្តរជាតិ។

សមាជិករាជវង្សានុវង្សក៏រក្សានូវទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយប្រជាពលរដ្ឋជប៉ុនតាមរយៈការចូលរួមក្នុងកម្មវិធីផ្សេងៗ នៅទូទាំងប្រទេស និងតាមរយៈការចុះសួរសុខទុក្ខប្រជាជនតាមមន្ទីរជនពិការ និងជនចាស់ជរា។ សមាជិករាជវង្សានុវង្សទទួលបាននូវការគោរពយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋជប៉ុន។



Imperial Household Agency

រាជវង្សានុវង្សរបស់ជប៉ុន (រូបថតក្នុងឆ្នាំ ២០១៧)
រូបពីឆ្វេង: ព្រះអង្គម្ចាស់ក្សត្រីយ៍ រាជទាយាទ ម៉ាសាកូ / ព្រះអង្គម្ចាស់ក្សត្រីយ៍ ម៉ាកូ / ព្រះអង្គម្ចាស់រាជទាយាទ ណារូហ៊ីតូ / ព្រះអង្គម្ចាស់ក្សត្រីយ៍ អៃកូ / ព្រះចៅអធិរាជ អាគីហ៊ីតូ / ព្រះរាជនី មីឈីកូ / ព្រះអង្គម្ចាស់ ហ៊ីសាហ៊ីតូ / ព្រះអង្គម្ចាស់ អាគីស៊ីណូ / ព្រះអង្គម្ចាស់ក្សត្រីយ៍ កាកូ / ព្រះអង្គម្ចាស់ក្សត្រីយ៍ អាគីស៊ីណូ

# ទង់ជាតិ និងភ្លេងជាតិ

ទង់ជាតិជប៉ុនត្រូវបានគេហៅថា ហ៊ីណូម៉ារូ។ គេបានចាប់ផ្តើមប្រើប្រាស់ទង់ជាតិនេះនៅចុងសតវត្សរ៍ទី១៩។ ទង់ជាតិបង្ហាញនូវរូបព្រះអាទិត្យជារង្វង់មូលពណ៌ក្រហមរំលេចនៅកណ្តាលផ្ទៃពណ៌ស។ ភ្លេងជាតិជប៉ុន "គីមីហ្គាយ៉ូ" មានដើមកំណើតពីកំណាព្យដែលមាន ៣១ព្យាង្គ ឬ ហៅថា វ៉ាកា ដែលត្រូវបាននិពន្ធឡើងក្នុងសតវត្សរ៍ទី១០។ ពាក្យពេចន៍នៃភ្លេងជាតិអធិប្បាយអំពីការបួងសួងសុំសន្តិភាព និងភាពសម្បូររុងរឿងជានិច្ចនិរន្តនៅក្នុងប្រទេសជប៉ុន។



## គីមីហ្គាយ៉ូ

Words: Anonymous
Music: Hayashi Hiromori



# ស្ថាប័នរដ្ឋ

រដ្ឋធម្មនុញ្ញជប៉ុនដែលបានចូលជាធរមានក្នុងឆ្នាំ១៩៤៧ ផ្អែកលើគោលការណ៍បីយ៉ាងគឺអធិបតេយ្យភាពរបស់ប្រជាជនការគោរសិទ្ធិមនុស្សជាមូលដ្ឋាន និងការលះបង់ចោលសង្គ្រាម។ ច្បាប់រដ្ឋធម្មនុញ្ញក៏បានចែងផងដែរពីឯករាជ្យភាពនៃស្ថាប័នទាំងបីរបស់រដ្ឋគឺ ស្ថាប័ននីតិបញ្ញត្តិ (សភាជាតិ) ស្ថាប័ននីតិប្រតិបត្តិ (គណៈរដ្ឋមន្ត្រី) និង ស្ថាប័នតុលាការ។



អគាររបស់សភាជាតិ

សភាជាតិរបស់ជប៉ុនគឺជាស្ថាប័នអំណាចកំពូលរបស់រដ្ឋ និងជាស្ថាប័នតាក់តែងច្បាប់តែមួយគត់របស់រដ្ឋ។ សភាជាតិជប៉ុនមានសភាតំណាងរាស្ត្រ (សភាជាន់ទាប) ដែលមាន៤៦៥អាសនៈ និងព្រឹទ្ធសភា (សភាជាន់ខ្ពស់) ដែលមាន២៤២តអាសនៈ។ ប្រជាពលរដ្ឋជប៉ុនទាំងអស់មានសិទ្ធបោះឆ្នោតនៅពេលពួកគេមានអាយុគ្រប់ ១៨ឆ្នាំ។

ប្រទេសជប៉ុនមានប្រព័ន្ធរដ្ឋាភិបាលអាស្រ័យដោយសភាដូចចក្រភពអង់គ្លេស និងប្រទេសកាណាដា។ ខុសពីពលរដ្ឋអាមេរិក ឬបារាំង ប្រជាពលរដ្ឋជប៉ុនមិនមានសិទ្ធិបោះឆ្នោតជ្រើសរើសប្រធានាធិបតីផ្ទាល់ទេ។ សមាជិកសភាបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រីក្នុងចំណោមសមាជិករបស់ខ្លួន។ នាយករដ្ឋមន្ត្រីបង្កើត និងដឹកនាំគណៈរដ្ឋមន្ត្រីរបស់រដ្ឋ។ គណៈរដ្ឋមន្ត្រីដែលមានអំណាចនីតិប្រតិបត្តិគឺត្រូវទទួលខុសត្រូវចំពោះមុខសភា។



សម័យប្រជុំពេញអង្គនៃសភាជាតិ

អំណាចតុលាការស្ថិតនៅនឹងតុលាការកំពូល ក្រៅពីនេះមានដូចជាសាលាឧទ្ធរណ៍ សាលាដំបូង និងសាលាលហុ។ តុលាការកំពូលមានប្រធានម្នាក់ និងចៅក្រម១៤នាក់ទៀត អ្នកទាំងអស់នោះត្រូវបានតែងតាំងដោយគណៈរដ្ឋមន្ត្រី។ រឿងក្តីភាគច្រើនត្រូវបានដោះស្រាយដោយសាលាដំបូង។ មានសាលាលហុដើម្បីដោះស្រាយបញ្ហាកម្រិតស្រាលដូចជាការរំលោភច្បាប់ចរាចរណ៍ជាដើម។

ប្រទេសជប៉ុនមានអាជ្ញាធរខេត្តចំនួន៤៧ និងមានអាជ្ញាធរក្រុងជាច្រើនដែលទទួលខុសត្រូវការងារអប់រំ សុខុមាលភាព សេវាផ្សេងៗ ការសាងសង់ និងការថែទាំជួសជុលហេដ្ឋារចនាសម្ព័ន្ធរួមទាំងសេវាផ្គត់ផ្គង់ទឹក ភ្លើង ហ្គាស ផងដែរ។ ការងារអាជ្ញាធររបស់ពួកគាត់គឺធ្វើឲ្យកាន់តែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយប្រជាជនតាមមូលដ្ឋាន។ ប្រធានអាជ្ញាធរគ្រប់គ្រងតំបន់នីមួយៗ និងសមាជិកសភាតាមមូលដ្ឋានត្រូវបានជ្រើសតាំងដោយប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈការបោះឆ្នោត។

## ស្ថាប័នទាំងបីរបស់រដ្ឋ



# សេដ្ឋកិច្ច ឧស្សាហកម្ម និងបច្ចេកវិទ្យា

**ជប៉ុន** ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចខ្លាំងបំផុតនៅលើពិភពលោក។ ផលិតផលក្នុងស្រុកសរុប (តម្លៃនៃទំនិញផលិតបានទាំងអស់ និងតម្លៃនៃសេវាកម្មសរុបនៅក្នុងប្រទេសជប៉ុន ក្នុងរយៈពេលមួយឆ្នាំ) គឺស្ថិតក្នុងលំដាប់ថ្នាក់ខ្ពស់ជាងគេទី៣នៅលើពិភពលោក ហើយម៉ាករបស់ផលិតផលជប៉ុនដូចជា តូយ៉ូតា សូនី ហ្វូជីហ្វីម និង ប៉ាណា សូនិក មានឈ្មោះល្បីល្បាញនៅទូទាំងសកលលោក។

នៅទំព័រនេះ យើងនឹងបង្ហាញបច្ចេកវិទ្យាមួយចំនួនដែលធ្វើឲ្យប្រទេសជប៉ុនរក្សាបានតំណែងកំពូល។







©RIKEN

## កុំព្យូទ័រទំនើប

កុំព្យូទ័រទំនើបជប៉ុន "ខេ" គឺមានថាមពលខ្លាំងបំផុតមួយនៅលើពិភពលោកដែលអាចបង្កើតការគណនាខ្ទង់១លានកោដិ ក្នុងពេលមួយវិនាទី ("ខេ"គឺតួអក្សរជប៉ុនដែលមានន័យថា$១០^{១៦}$)។ វាត្រូវបានប្រើប្រាស់ចាំបាច់បំផុតសម្រាប់ការគណនាថាមពល សីតុណ្ហភាព និងការស្រាវជ្រាវវិជ្ជាពេទ្យ និងការប៉ាន់ប្រមាណការខូចខាត។



## ស៊ីនកាន់សេន (រថភ្លើងល្បឿនលឿន)

រថភ្លើងដែលរត់នៅលើខ្សែរថភ្លើងស៊ីនកាន់សេន គឺរត់បានចម្ងាយជាង២០០គម/១ម។ រថភ្លើងដែលលឿនជាងគេគឺរថភ្លើងហាយ៉ាប៊ូសាដែលរត់ចម្ងាយ៣២០គម/១ម រត់ក្នុង តំបន់តូហុគឺ។ ទោះបីជារថភ្លើងនេះមានល្បឿនលឿនខ្លាំងយ៉ាងណាក៏ដោយ ក៏នៅតែមានសុវត្ថិភាពខ្ពស់ទៀងពេល និងជិះមានផាសុខភាព។



©Fuji Heavy Industries Ltd.

## អ្នករក្សាសុវត្ថិភាពរថយន្ត

រថយន្តជប៉ុនត្រូវបានជឿជាក់នូវសុវត្ថិភាពទូទាំងពិភពលោក ហើយរថយន្តទាំងនោះនឹងត្រូវបន្តបង្កើតអ្នករក្សាសុវត្ថិភាពដោយបច្ចេកវិទ្យាថ្មី និងកំពុងអភិវឌ្ឍបន្ថែមនូវប្រព័ន្ធការពារជីវិតដែលអាចគ្រប់គ្រងម៉ាស៊ីន និងហ្វ្រាំងរថយន្តដើម្បីបញ្ចៀសពីគ្រោះថ្នាក់ និងកាត់បន្ថយការខូចខាតដោយប្រការណាមួយ។

## រូបិយវត្ថុ





## ភាពខ្លាំងនៃសេដ្ឋកិច្ចជប៉ុន

ផលិតកម្មគឺជាចំណុចខ្លាំងមួយរបស់ជប៉ុន ប៉ុន្តែប្រទេសជប៉ុនមិនសូវមានធនធានធម្មជាតិទេ ដូច្នេះជាទូទៅគឺក្រុមហ៊ុនជប៉ុនត្រូវនាំចូលនូវវត្ថុធាតុដើម ហើយនាំចេញនូវផលិតផលសម្រេច។ ឧស្សាហកម្មចម្បងៗរួមមាន រថយន្ត គ្រឿងចក្រ កុំព្យូទ័រ និង ផលិតផលអេឡិចត្រូនិចប្រើប្រាស់ប្រចាំថ្ងៃ។ សេដ្ឋកិច្ចជប៉ុនបានឆ្ពោះទៅមុខដោយការច្នៃប្រឌិតថ្មី និងសមត្ថភាពបច្ចេកវិទ្យា។







### គិលានុបដ្ឋាកយិកាស្វ័យប្រវត្តិ

ជប៉ុនកំពុងត្រួសត្រាយការអភិវឌ្ឍមនុស្សយន្តដែលមានចលនាដូចមនុស្ស។ មនុស្សយន្តប្រភេទនេះគឺជាតម្រូវការចាំបាច់សម្រាប់រោងចក្រ និងការដ្ឋានសំណង់ ព្រមទាំងត្រូវបានរំពឹងទុកថាគិលានុបកដ្ឋាយិកាស្វ័យប្រវត្តិនេះនឹងអាចជួយសម្រាលបន្ទុកការងារថែទាំមនុស្សចាស់ជរាបានច្រើន។




### កាមេរ៉ាឌីជីថល

កាមេរ៉ាឌីជីថលជប៉ុនត្រូវបានបន្តផលិតឲ្យមានរូបរាងកាន់តែតូច និងស្រាលជាមុន។ ទន្ទឹមនឹងនេះកាមេរ៉ាត្រូវបានបង្កើតឲ្យមានមុខងារបច្ចេកវិទ្យាកាន់តែឆ្លាតវៃ និងងាយស្រួលប្រើជាងមុន។ ហេតុនេះ សព្វថ្ងៃទោះយើងមិនយល់ដឹងពីជំនាញថតរូប ក៏យើងអាចថតបានរូបភាពល្អដែរ។





រូបិយវត្ថុជប៉ុនត្រូវបានហៅថា "យ៉េន" ហើយវាជារូបិយវត្ថុដែលសំខាន់មួយចំណោមរូបិយវត្ថុជាច្រើនដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចពិភពលោក។ រូបិយវត្ថុយ៉េនមានក្រដាសប្រាក់ ១ពាន់ ២ពាន់ ៥ពាន់ និង១ម៉ឺន ព្រមទាំងប្រភេទកាក់ មាន ១យ៉េន ៥យ៉េន ១០យ៉េន ៥០យ៉េន និង១០០ យ៉េន។ ទាំងក្រដាសប្រាក់ និងកាក់មានការច្នៃម៉ូដយ៉ាងស្មុកស្មាញដែល ធ្វើឲ្យពិបាកបង្កើតរូបិយវត្ថុក្លែងក្លាយ។

### កសិកម្ម និង ការនេសាទ

ផលិតផលកសិកម្មសំខាន់របស់ជប៉ុនគឺស្រូវ ប៉ុន្តែ ក៏មានបន្លែផ្លែឈើជាច្រើន និងសាច់គោជាច្រើនប្រភេទ ព្រមទាំងផលដំណាំរបស់កសិករប្រចាំថ្ងៃផងដែរ។ នាវានេសាទជប៉ុនធ្វើការនេសាទបានត្រីជាច្រើនប្រភេទ ប៉ុន្តែដោយសារតែជប៉ុនមានចំនួនប្រជាជនច្រើន ដូច្នេះចំណីអាហារជាច្រើនត្រូវបាននាំចូល ។

# ប្រវត្តិមិត្តភាព ជប៉ុន-កម្ពុជា

## ទសវត្សរ៍ឆ្នាំ ១៩៥០



ឆ្នាំ១៩៥៣ទំនាក់ទំនងការទូតរវាងប្រទេសជប៉ុន និងកម្ពុជាត្រូវបានបង្កើត ឆ្នាំ១៩៥៥ ចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពជប៉ុនកម្ពុជាអំឡុងពេលព្រះរាជទស្សនកិច្ចផ្លូវរដ្ឋរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុនៅប្រទេសជប៉ុន

## ទសវត្សរ៍ឆ្នាំ ១៩៦០



JICA

វេជ្ជបណ្ឌិតជប៉ុននៅមន្ទីរពេទ្យមង្គលបុរី ខេត្តបន្ទាយមានជ័យ



JICA

ក្រុមអ្នកស្ម័គ្រចិត្តជប៉ុនបានបណ្តុះបណ្តាលក្រុមអ្នកហែលទឹកខេត្តបាត់ដំបង

## ទសវត្សរ៍ឆ្នាំ ១៩៧០



ពន្លាកម្ពុជាក្នុងពិព័រណ៍អន្តរជាតិនាទីក្រុងអូសាកាឆ្នាំ ១៩៧០



## ទសវត្សរ៍ឆ្នាំ ១៩៨០



មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសសន្តិភាព បង្កើតឡើងដោយអង្គការអន្តរជាតិស្ម័គ្រចិត្តជប៉ុន(JVC)

## ទសវត្សរ៍ឆ្នាំ ១៩៩០



ឆ្នាំ១៩៩១ សន្និសីទទីក្រុងតូក្យូស្តីពីសន្តិភាពនៅកម្ពុជា



JICA

ឆ្នាំ១៩៩៧ ស្ពានជ្រោយចង្វារត្រូវបានកសាងឡើងវិញដែលជាគម្រោងជំនួយដំបូងគេ ក្រោយសង្គ្រាមស៊ីវិលនៅកម្ពុជា

## ទសវត្សរ៍ឆ្នាំ ២០០០



JICA

ឆ្នាំ២០០១ ស្ពានគីហ្សូណាត្រូវបានសាងសង់ក្នុងខេត្តកំពង់ចាម



ឆ្នាំ២០០៧ចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគ អំឡុងពេលទស្សនកិច្ចរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅប្រទេសជប៉ុន

## ទសវត្សរ៍ឆ្នាំ ២០១០



ឆ្នាំ២០១០ ព្រះករុណាព្រះបាទនរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានយាងបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសជប៉ុន



ឆ្នាំ២០១២ មហោស្រពគីហ្សូណាជប៉ុន-កម្ពុជា លើកទី១ បានប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)



JICA

ឆ្នាំ២០១៤ ស្ពានត្សឹបាសាត្រូវបានសាងសង់ឡើងនៅអ្នកលឿង ខេត្តព្រៃវែង



ឆ្នាំ២០១៦ ជើងហោះហើរត្រង់ជប៉ុន-កម្ពុជា បានបើកដំណើរការជាលើកដំបូង ហើយនាំឲ្យចំនួនអ្នកទេសចរកម្ពុជាកើនឡើង៥០%ទៅកាន់ប្រទេសជប៉ុន



ឆ្នាំ២០១៧ នាយករដ្ឋមន្ត្រីជប៉ុននិងកម្ពុជាបានបញ្ជាក់ឡើងវិញនូវការពង្រឹង“ភាពជាដៃគូយុទ្ធសាស្ត្រ”

# ជប៉ុន និង កម្ពុជាក្នុងវិស័យសេដ្ឋកិច្ច

ពាណិជ្ជកម្មរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំដែលបច្ចុប្បន្ននេះ ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានការកើនឡើងខ្ពស់ដល់ទៅ៤ ដងក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។

ប្រទេសជប៉ុនគឺជាប្រទេសដៃគូនាំចូលធំលំដាប់ទី៦នៃប្រទេសកម្ពុជាហើយចំនួនទឹកប្រាក់នៃការនាំចូលពីប្រទេសជប៉ុនមកកាន់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៦ មានចំនួនប្រមាណ ៣០៧លានដុល្លាសហរដ្ឋអាមេរិក។ ក្នុងនោះផលិតផលនាំចូលចម្បងៗរួមមានរថយន្តគ្រឿងម៉ាស៊ីនជាដើម។

ដោយឡែកប្រទេសជប៉ុនក៏ជាប្រទេសដៃគូនាំចេញធំលំដាប់ទី៤នៅប្រទេសកម្ពុជាផងដែរ។ ក្នុងឆ្នាំ២០១៦ ចំនួនទឹកប្រាក់នៃការនាំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសជប៉ុនមានចំនួន១,២០៥លានដុល្លាសហរដ្ឋអាមេរិក។ ផលិតផលនាំចេញចម្បងៗមានដូចជា សំលៀកបំពាក់ ស្បែកជើង និងឧបករណ៍សម្ភារៈអគ្គិសនី។

ការវិនិយោគពីប្រទេសជប៉ុននៅក្នុងប្រទេសកម្ពុជាក៏មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ ចំនួនទឹកប្រាក់វិនិយោគរបស់ជប៉ុននៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៦ មានចំនួន៨២២លានដុល្លាសហរដ្ឋអាមេរិក។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះក៏មានការចាប់ផ្តើមធ្វើវិនិយោគវិស័យពិពិធកម្ម ដូចជាដែករណបលួសរថយន្ត (Wire harness) ក្បាលម៉ាស៊ីនខ្នាតតូច និងគ្រឿងបន្លាស់នាឡិកា ព្រមទាំងវិស័យផ្តល់សេវាកម្ម ដូចជាផ្សារទំនើបផងដែរ។

ទន្ទឹមនឹងការរីកចម្រើននៃទំនាក់ទំនងសេដ្ឋកិច្ចដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរ ចំនួនប្រជាជនជប៉ុនដែលរស់នៅក្នុងប្រទេសកម្ពុជា និងចំនួនសមាជិកសមាគមពាណិជ្ជកម្មជប៉ុននៅប្រទេសកម្ពុជា (JBAC)ក៏មានការកើនឡើងយ៉ាងទៀងទាត់ និងគួរឲ្យកត់សម្គាល់ផងដែរ។

ក្រាហ្វិក១




ឯកសារយោង: CIB, CSEZB

ក្រាហ្វិក២




ឯកសារយោង: MOFA, JBAC

ការវិនិយោគពីប្រទេសជប៉ុនមិនត្រឹមតែបានរួមចំណែកដល់ការធ្វើឲ្យប្រសើរឡើងនូវជីវភាពរបស់ប្រជាជនកម្ពុជាតាមរយៈការបង្កើតឱកាសការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយជម្រុញដល់ការអភិវឌ្ឍពិពិធកម្មនៃវិស័យឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជាផងដែរ។


JICA

សកម្មភាពរបស់កម្មការនីក្នុងរោងចក្រផលិតគ្រឿងម៉ាស៊ីនខ្នាតតូចមីនីបៀរ


JBAC

ការវិនិយោគនៅក្នុងវិស័យសេវាកម្ម


JBAC

ការវិនិយោគនៅក្នុងវិស័យផលិតកម្ម

# កិច្ចសហប្រតិបត្តិការ

ប្រទេសជប៉ុនកំពុងតែឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍប្រទេសកម្ពុជាលើវិស័យជាច្រើនផ្សេងៗគ្នា តាមរយៈកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ បើគិតទៅលើទំហំទឹកប្រាក់សរុបនៃជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុនមានចំនួន ៣,៤០០លាន ដុល្លាសហរដ្ឋអាមេរិកចាប់តាំងពីឆ្នាំ១៩៩១ ដល់ ២០១៥ ហើយប្រទេសជប៉ុនជាប្រទេសមួយចំណោមប្រទេសផ្តល់ជំនួយធំជាងគេបំផុត។ បច្ចុប្បន្ននេះ ប្រទេសជប៉ុនកំពុងអនុវត្តគម្រោងសហប្រតិបត្តិការផ្សេងៗ ដើម្បីគាំទ្រដល់គោលដៅរបស់កម្ពុជាគឺការក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ដោយយកចិត្តទុកដាក់ទៅលើ ទី១ ការលើកស្ទួយឧស្សាហកម្មដូចជាការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ទី២ ការតំកើនគុណភាពនៃជីវភាពរស់នៅប្រជាជនកម្ពុជាដូចជា វិស័យសុខាភិបាល និងប្រព័ន្ធទឹកស្អាត ទី៣ ការសម្រេចឲ្យមានសង្គមប្រកបដោយនិរន្តរភាពតាមរយៈការពង្រឹងអភិបាលកិច្ចល្អ។

ជាក់ស្តែង "ស្ពានមិត្តិភាពកម្ពុជា-ជប៉ុន" ឬ ប្រជាពលរដ្ឋខ្មែរទូទៅនិយមហៅថា "ស្ពានជ្រោយចង្វារ" ត្រូវបានសាងសង់រួចរាល់ជាស្ថាពរលើកដំបូងនៅឆ្នាំ១៩៦៧ ដោយជំនួយរដ្ឋាភិបាលជប៉ុន។ ស្ពាននេះត្រូវបានខូចខាតទាំងស្រុងដោយសង្គ្រាមស៊ីវិល និងជួសជុលឡើងវិញ ក្រោមជំនួយឥតសំណងទី១ របស់រដ្ឋាភិបាលជប៉ុន ក្រោយសង្គ្រាមស៊ីវិលឆ្នាំ១៩៩៤។

នាពេលបច្ចុប្បន្ន ស្ពាននេះ ទើបតែបញ្ចប់ការជួសជុលលើកទី២ ដែលចំណាយពេលប្រមាណ២ឆ្នាំ ក្រោមជំនួយរដ្ឋាភិបាលជប៉ុន ក្នុងគោលបំណងឲ្យស្ពាននេះ នៅគង់វង្សសម្រាប់ប្រជាជនកម្ពុជាប្រើប្រាស់រយៈពេល ៥០ឆ្នាំទៅមុខទៀត។

សន្តិភាព និងស្ថេរភាពរបស់ប្រទេសកម្ពុជាពិតជាមានអត្ថន័យសំខាន់សម្រាប់តំបន់ទាំងមូល ដូច្នេះហើយប្រទេសជប៉ុននឹងបន្តចូលរួមយ៉ាងសកម្មជាបន្តទៀតសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជា។

## ការអភិរក្សអង្គរ

ប្រទេសកម្ពុជាមានតំបន់អង្គរ ដែលជាមោទភាពរបស់ពិភពលោកទាំងមូល។ ប្រទេសជប៉ុនបានរួមចំណែកយ៉ាងសកម្មក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់នេះ។

នៅឆ្នាំ១៩៩៣ បន្ទាប់ពីតំបន់អង្គរត្រូវបានកំណត់ចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការ UNESCO ប្រទេសជប៉ុនបានរៀបចំបើកកិច្ចប្រជុំដ៏ធំមួយគឺ "សន្និសីទអង្គររដ្ឋាភិបាលស្តីអំពីកិច្ចគាំពារ និងអភិវឌ្ឍរមណីដ្ឋានប្រវត្តិសាស្ត្រអង្គរលើកទីមួយ" នៅទីក្រុងតូក្យូ។ កិច្ចប្រជុំមួយនេះបានសម្រេចបង្កើតនូវគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ (ICC) ដែលត្រូវបានប្រារព្ធធ្វើឡើង២ដងក្នុងមួយឆ្នាំ (ខែមិថុនា និងខែធ្នូ) ដើម្បីសម្របសម្រួលកម្មវិធីអភិរក្ស និងអភិវឌ្ឍជាមួយនិងបណ្តាប្រទេស និងអង្គការនានាដែលជាដៃគូពាក់ព័ន្ធ ហើយប្រទេសជប៉ុន និងប្រទេសបារាំងបានដើរតួនាទីដ៏សំខាន់ជាសហប្រធានរយៈពេល ២៥ឆ្នាំចាប់តាំងពីឆ្នាំ១៩៩៣។

ទន្ទឹមនឹងនេះ ប្រទេសជប៉ុនក៏បានអនុវត្តសកម្មភាពជួសជុលប្រាសាទអង្គរវត្ត និងប្រាសាទបាយ័នផងដែរ។ នៅឆ្នាំ១៩៩៤ រដ្ឋាភិបាលជប៉ុនបានបង្កើតក្រុមការងារសម្រាប់អភិរក្សអង្គរហៅកាត់ថា JSA។ ក្រុមនេះកំពុងសហការជាមួយអាជ្ញាធរអប្សរាក្រោមឈ្មោះ JASA ហើយធ្វើការនៅប្រាសាទបាយ័ន។

ក្រៅពីនេះ ប្រទេសជប៉ុនបានផ្តល់ជំនួយសម្ភារៈចាំបាច់ក្នុងដំណើរការស្តារឡើងវិញនូវស្ពានហាលខាងលិចនៃប្រាសាទអង្គរវត្តដល់អាជ្ញាធរអប្សរា ហើយសកម្មភាពស្តារឡើងវិញនេះ បានចាប់ផ្តើមដំណើរការក្រោមកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់សាកលវិទ្យាល័យសូហ្វីយ៉ាប្រទេសជប៉ុន នៅឆ្នាំ២០១៨។ មានស្ថាប័នផ្សេងៗទៀតនៃប្រទេសជប៉ុនក៏កំពុងរួមចំណែកតាមរយៈកិច្ចការអភិរក្សប្រាង្គប្រាសាទ ឬ ការស្រាវជ្រាវផងដែរ។



ស្ពានជ្រោយចង្វារក្នុងឆ្នាំ ១៩៩៣



ស្ពានជ្រោយចង្វារជួសជុលរួចក្នុងឆ្នាំ ២០១៩




សកម្មភាពជួសជុលនៅប្រាសាទបាយ័នដោយ JASA

# អតីតនិស្សិតអាហារូបករណ៍រដ្ឋាភិបាលជប៉ុន

ក្នុងគោលបំណងគាំទ្រដល់ការបណ្តុះបណ្តាលធនធានមនុស្ស និងការអភិវឌ្ឍនៅប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនបានផ្តល់អាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុនសម្រាប់យុវជនកម្ពុជាចាប់តាំងពីឆ្នាំ១៩៩២។ គិតត្រឹមខែមេសា ឆ្នាំ២០១៨ ចំនួននិស្សិតកម្ពុជាដែលបាននិងកំពុងបន្តការសិក្សានៅប្រទេសជប៉ុន ក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលជប៉ុនមានចំនួនសរុបកើនឡើងដល់ជាង ១១០០ នាក់។ យើងសូមណែនាំអតីតនិស្សិតបីរូបដែលបានបញ្ចប់ការសិក្សានៅប្រទេសជប៉ុន និងទទួលជោគជ័យនៅក្នុងអាជីពរបស់ខ្លួន និងបន្តសកម្មភាពដ៏លេចធ្លោក្នុងវិស័យផ្សេងៗគ្នា។

## លោកស្រីបណ្ឌិត អ៊ុំ រ៉ាវី



- សាកលវិទ្យាធិការរងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ១៩៩៥-២០០២:សាកលវិទ្យាល័យ សូហ្វីយ៉ា
- មុខវិជ្ជាសិក្សា: ផ្នែកសិក្សាតំបន់

តាមរយៈពាក្យមួយឃ្លា "មានតែការសិក្សាអប់រំទេដែលអាចចម្លងយើងឲ្យរួចចាកផុតពីភាពក្រីក្រ" ដែលជានិច្ចកាល វាបានដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ និងបានក្លាយជាកម្លាំងចលករដ៏សំខាន់ ជម្រុញឲ្យខ្ញុំ អ៊ុំ រ៉ាវី ខិតខំតស៊ូរៀនសូត្រ និងព្យាយាមប្រឹងប្រែងស្វែងរកចំណេះវិជ្ជាបន្ថែមដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេស ក៏ដូចជាអនាគតរបស់ខ្លួន។ បន្ទាប់ពីបានបញ្ចប់ការសិក្សាដោយជោគជ័យ ខ្ញុំបានវិលត្រឡប់មកបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញ។ នៅក្នុងឆ្នាំ២០០៤ ខ្ញុំត្រូវបានតែងតាំងជានាយិកាមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា- ជប៉ុន ដែលមជ្ឈមណ្ឌលនេះបានដើរតួយ៉ាងសំខាន់ក្នុងការចូលរួមចំណែកបណ្តុះបណ្តាលអភិវឌ្ឍធនធានមនុស្សប្រកបដោយសមត្ថភាព និងគុណភាព បន្តពង្រីកនិងពង្រឹងកិច្ចសហប្រតិបត្តិការ និងការស្វែងយល់ពីគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរកម្ពុជា-ជប៉ុន។ ចាប់តាំងពីឆ្នាំ២០១១ មកដល់បច្ចុប្បន្ន ខ្ញុំជាសាកលវិទ្យាធិការរងទទួលបន្ទុកទំនាក់ទំនងកិច្ចការអន្តរជាតិ ដែលជារៀងរាល់ឆ្នាំខ្ញុំបានសម្របសម្រួលបញ្ជូននិស្សិតក៏ដូចជាសាស្ត្រាចារ្យទៅសិក្សា និងបង្រៀននៅប្រទេសជប៉ុនក្រោមកម្មវិធីផ្លាស់ប្តូរ ជាមួយនឹងសាកលវិទ្យាល័យដៃគូនានា ហើយក៏បានរៀបចំទទួលស្វាគមន៍ក្រុមនិស្សិត និងសាស្ត្រាចារ្យជប៉ុនមកធ្វើទស្សនកិច្ចសិក្សា ក៏ដូចជាការមកសិក្សារបស់និស្សិតជប៉ុននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញដែរ។ ខ្ញុំមានមោទនភាពចំពោះការងារទាំងនេះណាស់ ដែលខ្ញុំអាចធ្វើជាស្ពានសម្រាប់ទំនាក់ទំនងរវាងកម្ពុជា និងជប៉ុន។ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាលជប៉ុនដែលតែងតែផ្តល់ជំនួយសម្ភារៈបច្ចេកទេស និងជំនួយផ្សេងៗទៀត ជាពិសេសការផ្តល់អាហារូបករណ៍ដល់រូបខ្ញុំ ក៏ដូចជានិស្សិតកម្ពុជាដទៃទៀត។

## លោកបណ្ឌិត ឆន់ វឌ្ឍនា



- នាយកសាលាជាតិកសិកម្មព្រែកលាប
- ១៩៩៩-២០០២: សាកលវិទ្យាល័យកសិកម្ម និងបច្ចេកវិទ្យាតូក្យូ
- ២០០៣-២០០៥: សាកលវិទ្យាល័យណាហ្គូយ៉ា
- មុខវិជ្ជាសិក្សា: សេដ្ឋកិច្ចកសិកម្ម

កាលនៅសិក្សា ខ្ញុំតែងកោតសរសើរគ្រូៗរបស់ខ្ញុំ ដោយគាត់ចេះ និងអាចរកបាននូវចម្លើយសម្រាប់គ្រប់ចង្ងល់របស់ខ្ញុំ។ ខ្ញុំស្រលាញ់ពួកគាត់ដូចជាឪពុកម្តាយរបស់ខ្ញុំ ហើយខ្ញុំតែងស្រមៃចង់ក្លាយជាគ្រូបង្រៀន។ ដូចសេចក្តីប្រាថ្នា ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើការនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មក្នុងឆ្នាំ១៩៩៦ បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនៅទីនោះ។ ដោយមើលឃើញថាចំណេះជាស្ពានឆ្ពោះទៅត្រើយនៃការអភិវឌ្ឍ ខ្ញុំបានស្វែងរកការសិក្សាបន្ថែមនៅបរទេស។ ខ្ញុំសប្បាយរីករាយ និងអរគុណដល់ប្រទេស និងជនជាតិជប៉ុនដែលបានជួយ និងបង្កលក្ខណៈងាយស្រួលឲ្យខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតដោយជោគជ័យនៅឆ្នាំ២០០៥។ បន្ទាប់ពីត្រឡប់ចូលមាតុប្រទេសវិញ ខ្ញុំបានដើរតួនាទីជាគ្រូបង្រៀន និងជាអ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម អង្គការ និង ក្រុមហ៊ុន។ ឆ្នាំ២០១៤ ខ្ញុំត្រូវបានតែងតាំងជានាយកសាលាជាតិកសិកម្មព្រែកលៀបជាទីដែលខ្ញុំត្រូវប្រឈម និងកំពុងហៅរកជំនួយពីមិត្តភ័ក្ត្ររួមទាំងមិត្តជប៉ុន និងផ្សេងៗទៀតដើម្បីជួយដល់ការលើកកម្ពស់គុណភាព និងរុញច្រានសាលាជាតិមួយនេះឲ្យឡើងដល់កម្រិតមួយថ្មី។ សូមស្វាគមន៍ការចូលរួមចំណែក និងសូមអរគុណទុកជាមុន។

## លោកបណ្ឌិត ឧទ្ធី មុនីរ័ត្ន



- អគ្គនាយក ក្រុមហ៊ុន ថៃវ៉ា សេយគី (ខេមបូឌា) ឧបភើរេសិនដែលជាក្រុមហ៊ុនផលិតគ្រឿងចក្រកសិកម្មដំបូងគេបំផុតក្នុងប្រទេសកម្ពុជា និងជាប្រធានសមាគមអតីតខ្មែរមកពីប្រទេសជប៉ុន
- ២០០២-២០១០: សាកលវិទ្យាល័យឈីបា
- មុខវិជ្ជា: ផ្នែកប្រភពធនធានទឹកនៅក្រោមដី

សម្រាប់ក្មេងកំព្រាឪពុក តាំងពីអាយុទើបបាន៧ថ្ងៃចូលរៀនដំបូងនៅសាលាគ្មានដំបូល គ្មានជញ្ជាំងនៅក្រោមដើមឈើដូចជារូបខ្ញុំ ការទៅសិក្សានៅសាកលវិទ្យាល័យលំដាប់អន្តរជាតិនៅក្នុងប្រទេសជប៉ុន ធ្វើឲ្យជីវិតរបស់ខ្ញុំមានការផ្លាស់ប្តូរស្ទើរតែ១៨០ដឺក្រេ ទាំងជីវភាពរស់នៅ ការគិតគូរ និងអត្តចរិក។ បច្ចុប្បន្នខ្ញុំបាទកំពុងតែព្យាយាមផ្ទេរបច្ចេកវិទ្យាក្នុងការផលិតគ្រឿងម៉ាស៊ីនពីប្រទេសជប៉ុនមកប្រទេសកម្ពុជាតាមរយៈការងារក្រុមហ៊ុន និងព្យាយាមផ្សារភ្ជាប់ទំនាក់ទំនង និងរឹតបន្ទឹងចំណងមិត្តភាពរវាងកម្ពុជា និងជប៉ុនតាមរយៈការងារសមាគម។ ខ្ញុំគិតថា វាជាការចាំបាច់ដែលយើងត្រូវផ្សព្វផ្សាយបង្ហាញឲ្យបានកាន់តែទូលំទូលាយអំពីវប្បធម៌ ប្រពៃណី កីឡា ពាណិជ្ជកម្មល្អៗ អំពីគ្នាទៅវិញទៅមកឲ្យប្រជាជាតិនៃប្រទេសទាំងពីរបានយល់កាន់តែច្បាស់។

# ដំណើរឆ្ពោះទៅកាន់ប្រទេសជប៉ុន

ប្រជាជនកម្ពុជាទាំងអស់អាចចេញចូលប្រទេសក្នុងតំបន់អាស៊ានបានដោយពុំចាំបាច់មានទិដ្ឋាការ។ ប៉ុន្តែប្រជាជនកម្ពុជាត្រូវតែមានទិដ្ឋាការទើបអាចទៅប្រទេសជប៉ុនបាន។ ព័ត៌មានស្តីពីការស្នើសុំទិដ្ឋាការ មានដូចខាងក្រោម៖

**ការស្នើសុំទិដ្ឋាការ**

ទិដ្ឋាការទេសចរណ៍ អ្នកដាក់ពាក្យស្នើសុំត្រូវមាន

១.លិខិតឆ្លងដែន

២.ពាក្យសុំទិដ្ឋាការចូលប្រទេសជប៉ុន ភ្ជាប់រូបថត (45mm x 45mm)

៣.គម្រោងកម្មវិធីស្នាក់នៅប្រទេសជប៉ុន

៤.លិខិតបញ្ជាក់សមតុល្យនៅធនាគារ ឬ សៀវភៅធនាគារ

សម្រាប់ព័ត៌មានលម្អិតអាចរកបានតាមគេហទំព័រដូចខាងក្រោម៖
http://www.kh.emb-japan.go.jp/consular/visa/visa-index-e.htm

**ព័ត៌មានបន្ទាប់បន្សំគួរដឹងមុនពេលទៅជប៉ុន**

រូបិយប័ណ្ណ 4,000៛ រៀល ប្រហែល 110¥ យ៉េន

តង់ស្យុងអគ្គិសនី 100V



រូបរាងព្រីភ្លើង

**ការចំណាយក្នុងដំណើរកំសាន្តសម្រាប់២នាក់**

សំបុត្រយន្តហោះ: $1,000 / ២នាក់

មធ្យោបាយធ្វើដំណើរ $600 / ២នាក់ / ៧ថ្ងៃ

ចំណីអាហារ $420 / ២នាក់ / ៧ថ្ងៃ




ការស្នាក់នៅ $700 / ២នាក់ / ៧ថ្ងៃ



© daj/amanaimages



© BUD international/amanaimages

សណ្ឋាគារ New Koyo: រួមបញ្ចូលអាហារពេលព្រឹក និងល្ងាច តម្លៃ ~$122 សម្រាប់មនុស្ស២នាក់

**សរុប: US$2,720 / ២នាក់**

ព័ត៌មានលម្អិតនៃការចំណាយក្នុងមធ្យោបាយការធ្វើដំណើរ ៖



© Book Inn-Hostel

"សណ្ឋាគារបន្ទប់ប្រអប់" មួយយប់ ~US$ 28

# ប្រតិទិនព្រឹត្តការណ៍ កម្មវិធីជប៉ុនដែលមាននៅកម្ពុជា

(អក្សរពណ៌ខៀវ ព្រឹត្តិការណ៍វប្បធម៌, អក្សរពណ៌ខ្មៅ ព័ត៌មានអាហារូបករណ៍ជប៉ុន)

| | | | |
|---|---|---|---|
| កុម្ភៈ | រយៈពេល៤ថ្ងៃ<br>ប្រែប្រួលតាមឆ្នាំ | មហោស្រពគីហ្សូណា<br>នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) |  |
| មេសា | ចុងខែ | បើកទទួលពាក្យអាហារូបករណ៍ជប៉ុន (MEXT Scholarship) | |
| កក្កដា | ប្រែប្រួលតាមឆ្នាំ | តាណាបាតា (ពិធីបុណ្យផ្កាយ)<br>ការប្រឡងចម្រៀងជប៉ុនណូដូជីម៉ាន់<br>នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) |  |
| តុលា | ប្រែប្រួលតាមឆ្នាំ | មហោស្រពរាំវង់ជប៉ុន<br>ពិពរណ៍ការសិក្សានៅប្រទេសជប៉ុន<br>នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) | |
| វិច្ឆិកា | ប្រែប្រួលតាមឆ្នាំ | មហោស្រពភាពយន្តជប៉ុន<br>នៅតាមរោងភាពយន្តមួយចំនួន |  |

ដើម្បីទទួលបានព័ត៌មានទាក់ទងនឹងព្រឹត្តិការណ៍កម្មវិធីវប្បធម៌ជប៉ុន និងព័ត៌មានអាហារូបករណ៍ជាដើម សូមចូលទៅកាន់ទំព័រហ្វេសបុករបស់ស្ថានទូតជប៉ុន Embassy of Japan in Cambodia ឬគេហទំព័រ www.kh.emb-japan.go.jp ។

**សំណួរ ចម្លើយខ្លីៗ**



១. តើឈ្មោះគីហ្សូណាដែលស្ថិតនៅខេត្តកំពង់ចាម មានអត្ថន័យដូចម្តេចជាភាសាខ្មែរ?
ក. នាគរាជ ខ. សន្តិភាព គ. ចងចិត្ត



២. តើភ្នំហ្វូជិដែលខ្ពស់ជាងគេនៅប្រទេសជប៉ុន មានកម្ពស់ប៉ុន្មាន?
ក. ១៨១៣ម៉ែត្រ ខ. ៣៧៧៦ម៉ែត្រ គ. ៨៨៤៨ម៉ែត្រ



ចម្លើយនៅទំព័រមាតិកា

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

www.kh.emb-japan.go.jp
Embassy of Japan in Cambodia

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
រក្សាសិទ្ធគ្រប់យ៉ាង

ការបោះពុម្ពលើកទីX। ខែមករា ឆ្នាំ២០២០
ភាសាខ្មែរបោះពុម្ពនៅប្រទេសកម្ពុជា